**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៩៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែសម្រួលមាត្រា ៨ មាត្រា ១០ មាត្រា ១២ និងឧបសម្ព័ន្ធ នៃអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# **សម្រេច**

**មាត្រា មួយ.-**

ត្រូវបានកែសម្រួលមាត្រា ៨ មាត្រា ១០ មាត្រា ១២ និងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដូចតទៅ៖

**មាត្រា ៨ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានរចនាសម្ព័ន្ធដូចតទៅ៖

- ផ្នែកប្រព័ន្ធលាភការ
- ផ្នែកទីភ្នាក់ងារប្រតិបត្តិការពិសេស
- ផ្នែកត្រួតពិនិត្យ និង វាយតម្លៃ តាមវិស័យ
- ផ្នែកអភិវឌ្ឍធនធានមនុស្ស
- ផ្នែកវិចារណកម្មរចនាសម្ព័ន្ធ និង ដំណើរការ
- ផ្នែកផែនការសកម្មភាពអភិបាលកិច្ច
- ផ្នែកសេវាសាធារណៈ
- ផ្នែកព័ត៌មាន និង ផ្សព្វផ្សាយ
- ផ្នែកគ្រប់គ្រងធនធានមនុស្ស
- ផ្នែកតារាងទូទាត់បៀវត្សរ៍
- ផ្នែកគ្រប់គ្រងមន្ត្រីរាជការ តាមប្រព័ន្ធព័ត៌មានវិទ្យា
- ផ្នែកអធិការកិច្ច និងពង្រាយមន្ត្រីរាជការ
- ផ្នែកត្រួតពិនិត្យក្របខណ្ឌ
- ផ្នែក រដ្ឋបាលបុគ្គលិក និង ជំនួយការច្បាប់
- ផ្នែកផ្គត់ផ្គង់ និងហិរញ្ញកិច្ច និង
- ផ្នែកទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ

អង្គការលេខថ្មីរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ១០ថ្មី.-**

ផ្នែកប្រព័ន្ធលាភការ មាន ភារកិច្ច ដូចតទៅ ៖

- សិក្សា និងស្រាវជ្រាវ អំពីបទពិសោធន៍ដែលពាក់ព័ន្ធទៅនឹងការអនុវត្តប្រព័ន្ធលាភការ
- រៀបចំគោលនយោបាយលាភការ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- តាមដានការអនុវត្តគោលនយោបាយលាភការ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ប្រគល់ជូន ។

**មាត្រា ១២ថ្មី.-**

ផ្នែកត្រួតពិនិត្យ និង វាយតម្លៃតាមវិស័យ មានភារកិច្ច ដូចតទៅ ៖

- រៀបចំផែនការកម្ម នៃការអនុវត្តប្រព័ន្ធលាភការ និង ទីភ្នាក់ងារប្រតិបត្តិការពិសេស
- តាមដាន ធ្វើអធិការកិច្ច និង វាយតម្លៃលើការអនុវត្តប្រព័ន្ធលាភការ និងទីភ្នាក់ងារប្រតិបត្តិការពិសេស
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និង លទ្ធផលការងារសម្រេចបាន
- លើកអនុសាសន៍កែសម្រួលគោលនយោបាយ និង នីតិវិធីអនុវត្តប្រព័ន្ធលាភការ និងទីភ្នាក់ងារប្រតិបត្តិការពិសេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ប្រគល់ជូន ។

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី

## អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

